ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៨៥/១៧ ស.ប.ក

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមេសា និងទិសដៅខែឧសភា ឆ្នាំ២០១៧

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាន និងកំពុងខិតខំយកចិត្តទុកដាក់ ជំរុញ ពង្រឹងកិច្ចសហប្រតិបត្តិការ សម្របសម្រួលជាមួយបណ្ដាក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រេចបានលទ្ធផលជាច្រើន ដែលជាមោទនភាពសម្រាប់ការងារប្រយុទ្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទូទាំងប្រទេស ។ គ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ដើម្បីសម្រេចបាននូវគោលដៅផែនការរបស់ខ្លួន។ តែយើងនូវមានការខ្វះខាតខ្លះដែលបណ្ដាក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មួយចំនួនមិនទាន់បែកដាច់ការងារ ដែលទាក់ទងនឹងខ្លឹមសារ ផ្ដោតសំខាន់លើការងារប្រយុទ្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ដូចនេះស្នើសុំឲ្យក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពិនិត្យឡើងវិញការផ្ដល់របាយការណ៍របស់ខ្លួនមកអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ហើយរបាយការណ៍ក្រសួង និងខេត្តមួយចំនួនត្រូវផ្ញើមកឲ្យបានទាន់ពេលកំណត់ តែក្រសួង និងខេត្តមួយចំនួនមានការយឺតយ៉ាវ ហើយបើយោងសេចក្ដីសម្រេចលេខ០៨៤/១៤ ស.ស.រ ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសេចក្ដីសម្រេចលេខ០០១/១៤ ស.ស.រ ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ បូកសរុបរបាយការណ៍ដែលប្រមូលបានពីក្រុងស្រុកខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ ប្រចាំខែ ត្រីមាស និងឆ្នាំ ស្ដីពីសកម្មភាព លទ្ធផល ភាពប្រឈម ជុំវិញការប្រឆាំងអំពើជួញដូរមនុស្ស និងទិសដៅ ដាក់ជូនអភិបាលរាជធានី ខេត្តដែលជាប្រធាន គ.រ.ប.ជ ឬ គ.ខ.ប.ជ ដើម្បីពិនិត្យ និងចុះហត្ថលេខារួចបញ្ជូនទៅអគ្គលេខាធិការដ្ឋានថ្នាក់ជាតិ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ។ របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបានគឺ ៖

- សម្រាប់បណ្ដាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានអគ្គស្នងការដ្ឋាននគរបាលជាតិ(ក្រុមការងារអនុវត្តន៍ច្បាប់) មួយគត់ដែលបានផ្ដល់របាយការណ៍ ។ ដោយឡែកក្រសួង ស្ថាប័ន ចំនួន៥ ដែលជាយន្តការសម្របសម្រួលការងារដឹកនាំ និងអនុវត្ត ដើម្បីធានាឲ្យមានកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតមិនទាន់បានផ្ញើរបាយការណ៍។
- សម្រាប់បណ្ដាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋានរាជធានី/ខេត្តចំនួន២៣ ដែលបានផ្ដល់របាយការណ៍ដូចជា៖ រាជធានីភ្នំពេញ ,ខេត្តកោះកុង ព្រះសីហនុ កំពត កែប តាកែវ កណ្ដាល ព្រៃវែង

Sitha

ស្វាយរៀង ឧត្តរមានជ័យ ប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ ព្រះវិហារ សៀមរាប កំពង់ធំ ក្រចេះ ស្ទឹងត្រែង រតនគិរី កំពង់ចាម ត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង។ ដោយឡែកលេខាធិការដ្ឋានខេត្តចំនួន ២គឺ ខេត្តកំពង់ស្ពឺ និងខេត្តមណ្ឌលគិរី នៅមិនទាន់បានផ្ញើរបាយការណ៍។

## II. ការអនុវត្តតាមផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ(២០១៤-២០១៨)

### ក.ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ដើម្បីសម្រេចបានតាមផែនការ យុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨) អគ្គលេខាធិការដ្ឋាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយក្រសួង ស្ថាប័ន ជំនាញ ដៃគូពាក់ព័ន្ធជាតិ អន្តរជាតិ ក្នុងនោះមានស្ថានទូតផងដែរសម្រេចបានលិខិតបទដ្ឋានគតិយុត្តិមួយចំនួនដូចខាងក្រោម៖

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានត្រៀមពិភាក្សាលើផែនការអនុវត្តកិច្ចព្រមព្រៀង កម្ពុជា-ឥណ្ឌា ស្តីពី«កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» ។
- ក្រសួងកិច្ចការនារី បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី "ការគ្រប់គ្រងការពពោះជំនួស"
- ក្រសួងយុត្តិធម៌ បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ"
- ក្រសួងអប់រំ យុវជន និងកីឡា បាន និងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"

### ខ.លើកកម្ពស់ការបង្ការទប់ស្កាត់

ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយវេទិកាសាធារណៈ តាមប្រធានបទ "ភូមិឃុំមានសុវត្ថិភាព" បានចំនួន២.៩២៩លើក ថយចុះចំនួន២៦៣លើក ស្មើនឹង៨,២៣% (ធៀបនឹងខែមុនបានចំនួន៣.១៩២លើក) មានអ្នកចូលរួមសរុបចំនួន៣៤២.៤៣០នាក់ ថយចុះចំនួន១៧៧.៣៨៣នាក់ ស្មើនឹង៣៤,១២% (ធៀបនឹងខែមុនមានតែចំនួន៥១៩.៨១៣នាក់) ក្នុងនោះស្ត្រីមានចំនួន ១៦៦.៤៣២នាក់ ។ (ឧបសម្ព័ន្ធទី១)

#### ខ.១-ការផលិត និងចែកផ្សាយសម្ភារៈផ្សព្វផ្សាយ

- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបាត់ដំបង បានសហការជាមួយអង្គការសាម៉ារីតាន់ភឺស បានផ្តល់សៀវភៅព័ត៌មាន ស្តីពីការធ្វើចំណាកស្រុក សម្រាប់ដោះស្រាយបញ្ហាមុនពេល និងកំពុងធ្វើចំណាកស្រុក ។

#### ខ.២-ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន

- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានធ្វើការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធការជួញដូរមនុស្ស និងបទល្មើសផ្សេងៗ តាមប៉ុស្តិ៍វិទ្យុ បានចំនួន០៤លើក។

### គ.ការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍

#### គ.១-ការគ្រប់គ្រងបច្ចុប្បន្នភាពស្ថិតិចំណាកស្រុក

របាយការណ៍ពីអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានចុះធ្វើស្ថិតិពលករចំណាកស្រុកទៅក្រៅប្រទេស៖

សរុបមានចំនួន៣២៣.៨១៨នាក់ (ស្រី១៤០.០០២នាក់) អនីតិជន ៨.៦៤៤នាក់ (ស្រី៣.៤៤៤នាក់) ក្នុងនោះចំណាកស្រុកស្របច្បាប់មានចំនួន១៨៣.៩០៤នាក់(ស្រី៨៣.៨៣៩នាក់) អនីតិជនចំនួន១.៣០៨នាក់

(ស្រី៥៧៧នាក់) និងចំណាកស្រុកមិនស្របច្បាប់មានចំនួន១៣៩.៩១៤នាក់ (ស្រី៥៦.១៦៣នាក់) អនីតិជនមានចំនួន៧.៣៣៦នាក់(ស្រី២.៨៦៧នាក់)។ ស្ថិតិនេះប្រៀបធៀបនឹងខែមុន(មីនា)កើនឡើងចំនួន២.៦៥៩នាក់ ស្មើនឹង០,៨២៧% ។

គ.២-ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសឯកជន បញ្ជូនពលករទៅធ្វើការនៅបរទេស

ក្រុមហ៊ុនឯកជន TOUCH MANAK MANPOWER SUPPLY CO.LTD បានជ្រើសរើសពលករទៅធ្វើការនៅប្រទេសថៃ ដោយស្របច្បាប់ ចំនួន ០១ លើក ពលករមានចំនួន១១នាក់(ស្រីចំនួន០២នាក់)។

គ.៣-ស្ថានភាពលំហូរជនទេសន្តប្រវេសន៍

ខេត្តបន្ទាយមានជ័យ ក្រុមការងារទទួលជនទេសន្តប្រវេសន៍ថា ថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញក្រោមរូបភាព «និរទេស» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន៣២៣ជើងរថយន្ត មានពលករខ្មែរសរុបចំនួន១៤.៩០១នាក់ (កើនឡើងចំនួន៨.៧៦៩នាក់បើប្រៀបធៀបនឹងខែមីនា) ស្រីចំនួន៥.៣០៦នាក់ ក្នុងនោះកុមារចំនួន១.៣២៦នាក់ (កុមារី៥៨៧នាក់)។ ការសម្ភាសន៍ខ្លី បានកើឃើញថា៖

បានចេញតាមច្រកអន្តរជាតិប៉ោយប៉ែត ៦.៥៩៨ នាក់ តាមច្រករបៀង ៨.៣០៣ នាក់

ចេញដោយខ្លួនឯង ៧.០៧៧ នាក់ តាមរយៈគេនាំ ៧.៨២៤ នាក់

បានជាប់ពន្ធនាគារ លើសពី ១ខែ មានចំនួន ៥៣៧ នាក់ ។ ពួកគាត់មានខ្លះជាប់ឃុំរយៈពេល១៥ឆ្នាំ, ១២ឆ្នាំ ០៨ ឆ្នាំ ដោយមូលហេតុខ្លះស៊ីឈ្នួលកាន់គ្រឿងញៀន ខ្លះចូលទៅលួចកាប់ឈើគ្រញូង ខ្លះស៊ីឈ្នួលដឹករបស់ក្លែងក្លាយ ខ្លះកាន់ប៉ាស្ព័ររូបអ្នកផ្សេង ដែលមេខ្យល់ឲ្យកាន់ អ្នកគ្មានប័ណ្ណស្នាក់នៅត្រូវជាប់រយៈពេល២ខែ។

ក្រុមការងារបានសម្ភាសពលករបន្តចំនួន៦០៤នាក់ (ស្រី២៦៣នាក់) មិនបានកើឃើញអត្តសញ្ញាណជនសង្ស័យនាំមនុស្សឆ្លងដែនទេ។ ការសម្ភាសកុមារចំនួន៩៤នាក់ (កុមារី ៣៧នាក់) បានកើឃើញកុមារ៥៥នាក់ ទៅតាមឪពុកម្តាយ និងកុមារ៣៩នាក់ ទៅតាមបងប្អូន ។

គ.៤-វិធានការគ្រប់គ្រងជំនាញ

គ.៤.១-ការងារបង្ក្រាបទប់ស្កាត់តាមវិធានការជំនាញរបស់អគ្គស្នងការនគរបាលជាតិ

- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងខេត្តស្វាយរៀង បានចុះធ្វើស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តអំពើសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារ ក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន៤៥១គោលដៅ មានមនុស្សធ្វើការចំនួន១.៧៩៩នាក់ (ស្រី១.៤១៧នាក់)។ បានធ្វើតាមដាន និងឃ្លាំមើលបានចំនួន ៤៥១គោលដៅ ថយចុះ១៥៦គោលដៅ បើប្រៀបធៀបខែមុនមានចំនួនតែ ៦០៧គោលដៅ ស្មើនឹង ២៥,៧០% ពិនិត្យឃើញមានមនុស្សធ្វើការចំនួន១.៧៩៩នាក់ ថយចុះចំនួន១.៨៤២នាក់ ស្មើនឹង៥០.៥៩% (ស្ត្រី១.៤១៧នាក់)បើប្រៀបធៀប ខែមុន មានចំនួនតែ៣.៦៤១នាក់ ។
- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការបង្ក្រាបទប់ស្កាត់ពលករខ្មែរធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ បានចំនួន០៣លើក មានមនុស្សចំនួន១៣៣នាក់(ស្រី៣១នាក់ អនីតិជន ១០នាក់) ក្រោយពីពេលធ្វើការសាកសួរ អប់រំ ណែនាំ និងបានធ្វើកិច្ចសន្យា ហើយបានឲ្យពួកគាត់វិលទៅរកលំនៅដ្ឋានវិញ ។
- ស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន បានធ្វើការបង្ក្រាបទប់ស្កាត់ប្រជាពលរដ្ឋខ្មែរធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ នៅចំណុចផ្សារព្រំជាប់ព្រំដែន បានចំនួន៥៨ នាក់(ស្រី២៦នាក់ កុមារ០៥នាក់)
- ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម បានចុះចលនាដល់បណ្តាញភ្នាក់ងារ បិទស្លាក ដើម្បីសុវត្ថិភាពកុមារ

លើម៉ូតូកង់៣បានចំនួន១៩គ្រឿង និងម៉ូតូឌុបចំនួន២៥គ្រឿង ព្រមទាំងបានបំពេញទម្រង់ពិនិត្យភ្នាក់ងារសុវត្ថិភាពកុមារ ចំនួន០៩នាក់ ។

- ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ អង្គការម្លប់តាប៉ាង បានចុះចលនាដាក់បណ្ដាញភ្នាក់ងារដើម្បីសុវត្ថិភាពកុមារ លើក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី បណ្ដាញសហគមន៍ បណ្ដាញអ្នកលក់តាមឆ្នេរសមុទ្រ បុគ្គលិកតាមផ្ទះសំណាក់ និងសណ្ឋាគារ សរុបចំនួន៦២៧នាក់ ។
- បច្ចុប្បន្នភាព ទិន្នន័យគោលដៅសង្ស័យ ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ នៅរាជធានី-ខេត្ត មានចំនួន៧៥គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សមានចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ ។

គ.៤.២-ការបង្ការទប់ស្កាត់តាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

របាយការណ៍ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ជាសេនាធិការ បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ចំនួន១៣៦គូ និងបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់ទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេស ចម្លើយការរស់នៅជាមួយគ្រួសារមានសេចក្ដីសុខសប្បាយជាធម្មតា។

## ឃ.ការពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបនៅនឹងអំពើជួញដូរមនុស្ស

ឃ.១ ការងារអនុវត្តច្បាប់

ឃ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

ក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការដ្ឋាននគរបាលជាតិ) បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន៧ករណី/១២ករណី(បើប្រៀបធៀបខែមុនថយចុះ០៥ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន០៨នាក់(ស្រី០១នាក់) សង្គ្រោះជនរងគ្រោះបានចំនួន៣៧នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន៣១នាក់ អាយុពី១៥-១៧ឆ្នាំចំនួន០២នាក់ និងអាយុ១៨ឆ្នាំឡើងបានចំនួន០៤នាក់ (បានប្រគល់ឲ្យទៅគ្រួសារវិញទាំងអស់) ។

- ការបង្ក្រាបអំពើជួញដូរមនុស្ស

សរុបបាន០២ករណី/០១ករណី ជនសង្ស័យចំនួន០៣នាក់(ស្រី០១នាក់) ជនរងគ្រោះបានចំនួន១៤នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន០៩នាក់ អាយុពី១៥-១៧ឆ្នាំចំនួន០១នាក់ និងអាយុ១៨ឆ្នាំឡើងមានចំនួន០៤នាក់ (ហើយបានប្រគល់ឲ្យគ្រួសារវិញ) ។

- នាំយកចេញដោយមិនស្របច្បាប់មានគោលដៅ ០១ករណី ជនសង្ស័យ ០១នាក់
- ការទិញពេស្យាចារកុមារ ០១ករណី ជនសង្ស័យ ០១នាក់

- ការបង្ក្រាបអំពើធ្វើអាជីវកម្មផ្លូវភេទ

សរុប០៥ករណី/១១ករណី ជនសង្ស័យចំនួន០៥នាក់ ក្នុងនោះជនរងគ្រោះចំនួន២៣នាក់ អាយុក្រោម១៥ឆ្នាំចំនួន២២នាក់ អាយុពី១៥-១៧ឆ្នាំ០១នាក់ (ហើយបានប្រគល់ឲ្យគ្រួសារវិញ) ។

-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ០៤ករណី ជនសង្ស័យ ០៤នាក់

-មានរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ០១ករណី ជនសង្ស័យ ០១នាក់

ឃ.២ កិច្ចការយុត្តិធម៌

ឃ.២.១ លទ្ធផលចំណាត់ការផ្ដន្ទាទោស(ពុំមានទិន្នន័យ)

ឃ.២.២-ការរៀបចំបទដ្ឋានគតិយុត្តិ និងច្បាប់ Ptha

- សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលរុស្ស៊ី ។
- សេចក្តីព្រាងកិច្ចព្រមព្រៀង ស្តីពី "បញ្ជូនទណ្ឌិត" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស និង រដ្ឋាភិបាលប៉េរូ និងសាធារណរដ្ឋប្រជាមានិតឡាវ និង រដ្ឋាភិបាលរុស្ស៊ី ។

## ង.កិច្ចការពារជនរងគ្រោះ ព្រមទាំងសេវាគាំទ្រ

ង.១- ស្ថិតិពលករដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេស តាមច្រកព្រំដែន

របាយការណ៍ទទួលពីក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការនគរបាលជាតិ) ពលករទេសន្តរប្រវេសន៍ ការងារបញ្ជូនត្រឡប់មកពីច្រកព្រំដែនកម្ពុជា-ថៃ និងច្រកព្រំដែនកម្ពុជា-វៀតណាម សរុបចំនួន ៤៩.៦១៧នាក់ (ស្រី២២.៧៨៥នាក់)អនីតិជនចំនួន១.៤២៩នាក់ (ស្រី៥៨៦នាក់) ដែលមកតាម ៖

- ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ១៣.៥០០នាក់(ស្រី ៤.៨២៥នាក់ ,អនីតិជន១.១៨៦នាក់ (ស្រី៥៣០នាក់)
- ច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបងចំនួន៣៤.៨៧៤នាក់ (ស្រី១៣.៧៧៥នាក់ ,កុមារ១២៣នាក់)
- ច្រកភ្នំដី ស្រុកសំពៅលូន ខេត្តបាត់ដំបងចំនួន១.២៤០នាក់(ស្រី៤.១៨៥នាក់,កុមារ១២០នាក់,កុមារី៥៦នាក់)
- ច្រកអានសេះ ខេត្តព្រះវិហារ០៣នាក់

ក្នុងនោះពលរដ្ឋខ្មែរចំនួន៣៩៣នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុន និងបញ្ជូនមកកម្ពុជាវិញ ។ហើយបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅឋានវិញ ។

ង.២-ការសម្ភាសពលករចាប់បញ្ជូនត្រឡប់តាមច្រកព្រំដែន(ផ្លូវគោក និងផ្លូវអាកាស)

- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានសម្ភាសដើម្បីកំណត់អត្តសញ្ញាណកម្មុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលប្រទេសថៃបញ្ជូនមក បានចំនួន១៦នាក់(ស្ត្រី០៥នាក់) ក្នុងនោះមានកុមារចំនួន១១នាក់(កុមារី០៧នាក់)មកជាមួយគ្រួសារ ។

បញ្ជាក់៖ - ចំនួន១៥នាក់ ជាករណីងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និង
- កុមារី០១នាក់ រងគ្រោះដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម។

- ក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការដ្ឋាននគរបាលជាតិ)បានស្រង់ឈ្មោះជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស មានចំនួន១៥នាក់ ទៅតាមរយៈមេខ្យល់ ក្នុងនោះ៖
  - មកពីប្រទេសថៃ ចំនួន០៣នាក់
  - មកពីប្រទេសម៉ាឡេស៊ី ចំនួន០៧នាក់
  - មកពីប្រទេសចិន ចំនួន០៥នាក់
- ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានស្រង់ឈ្មោះជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស តាមរយៈក្រសួងការបរទេស មានចំនួន០៨នាក់ ក្នុងនោះ៖
  - មកពីប្រទេសម៉ាឡេស៊ី ចំនួន០៦នាក់ (ស្រី០៤នាក់)
  - មកពីប្រទេសចិន ចំនួន០២នាក់ (ស្រី០២នាក់)

ង.៣ ការគ្រប់គ្រងជនងាយរងគ្រោះនៅក្នុងមណ្ឌល

រាជធានីភ្នំពេញ បានទទួលជនអនាថាមិនស្ម័គ្រចិត្តសរុបចំនួន១៣១នាក់ (ស្រី២៥នាក់ ,កុមាចំនួន ២០នាក់

កុមារី០៣នាក់ ដោយបានបញ្ជូនជនរងគ្រោះទាំងនេះ ទៅមណ្ឌលសំចតនៅមន្ទីរ ស.អ.យ រាជធានីភ្នំពេញ ចំនួន១២៩នាក់(ស្រី២៤នាក់ ,កុមារា១៦នាក់ ,កុមារី០២នាក់) និងមណ្ឌលឱកាសខ្ញុំចំនួន០៣នាក់ ដើម្បីអប់រំ និងបណ្ដុះបណ្ដាលរយៈពេលខ្លី មុននឹងសមាហរណកម្មទៅសហគមន៍វិញ ។

ង.៤ សេវាជួយជនរងគ្រោះដែលបានផ្ដល់

មណ្ឌលសំចត ខេត្តបន្ទាយមានជ័យ បានបញ្ជូនជនរងគ្រោះ១៧នាក់ ទៅអង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិចំនួន១៥នាក់ ក្នុងនោះមានស្ត្រី០៥នាក់,កុមារី០៦នាក់,កុមារា០៤នាក់។ អង្គការដំណក់ទឹក កុមារី០១នាក់ និងផ្ទះសហគមន៍របស់អង្គការ A21 ស្ត្រី០១នាក់ ដើម្បីបានទទួលសេវាស្នាក់នៅសុវត្ថិភាពអប់រំក្នុង និងក្រៅប្រព័ន្ធបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈនិងសេវាផ្សេងៗ ។

ង.៥ សមាហរណកម្មជនរងគ្រោះ

- មន្ទីរសង្គមកិច្ច ស.អ.យ ខេត្តបាត់ដំបង គ្រប់ស្រុក បានចុះពិនិត្យ និងសហការជាមួយអង្គការដៃគូធ្វើការប៉ាន់ប្រមាណជនងាយរងគ្រោះ ដែលធ្វើសមាហរណកម្ម ចំនួន០៥នាក់ ក្នុងនោះចំនួន០៣នាក់បានបញ្ជូនទៅមណ្ឌលសុខភាពរបស់អង្គការដើម្បីទទួលសេវាថែទាំ និងជនរងគ្រោះចំនួន០២នាក់ទៀតបានបញ្ជូនឲ្យទៅរស់នៅក្នុងសហគមន៍វិញ ។

## III. ការលើកកម្ពស់សមត្ថភាព

### ក.ក្នុងប្រទេស

ក.១-បណ្ដុះបណ្ដាល

- ខេត្តកំពង់ចាម ៖ ក្រុមការងារថ្នាក់ស្រុក បានបើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់បណ្ដាញសហគមន៍នៅស្រុកចម្ការលើ បានចំនួន០១វគ្គ មានសិក្ខាកាមចំនួន៤៦នាក់ (ស្រី២៥នាក់)។
- ខេត្តស្វាយរៀង ៖ ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃមន្ទីរសង្គមកិច្ច និងនាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស បានបើកវគ្គបណ្ដុះបណ្ដាលច្បាប់ ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០១លើក ដល់អធិការរង នាយផ្នែក នាយប៉ុស្តិ៍ នៅស្រុកចន្ទ្រា និងស្រុកកំពង់រោទ៍ មានសិក្ខាកាមចំនួន៣០នាក់ (ស្រី០៧នាក់)។

ក.៣-សម្របសម្រួលកិច្ចប្រជុំ

ការងារដឹកនាំសម្របសម្រួលសរុបបានចំនួន៣៤លើកៈ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន១២លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន២២លើក ។ (ឧបសម្ព័ន្ធទី២)

### ខ.ក្រៅប្រទេស

ខ.១ សកម្មភាពចូលរួមប្រជុំ

◦ខេត្តរតនគិរី បានចូលរួមប្រជុំថ្នាក់ប៉ុស្តិ៍នៃ(វរៈការពារព្រំដែនលេខ៦២៣ និង២០៣)ជាមួយភាគីឡាវ និងភាគីវៀតណាម ស្ដីពីកិច្ចសហប្រតិបត្តិការ រក្សាសន្តិសុខ សណ្ដាប់ធ្នាប់តាមបណ្ដោយព្រំដែន និងបញ្ហាប្រជាជន ឆ្លងដែនខុសច្បាប់ បានចំនួន១០៩លើក ។

ខ.២-សិក្ខាសាលា

◦លោកជំទាវឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធ

ប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញចូលរួមសិក្ខាសាលាវេទិកាតំបន់អាស៊ាន ស្តីពីការជួញដូរមនុស្ស (នៅប្រទេសឥណ្ឌូនេស៊ី)។

## គ.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធានគ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងសមាសភាពទាំងមូលដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ស្កាត់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា សត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងកម្លាំង និងការជួយឧបត្ថមពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ឃ.ចំណុចខ្វះខាត

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណាដែលទាក់ទងនឹងអំពើជួញដូរមនុស្ស។ ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាពបានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រី

ធ្វើបោយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែលក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

**ខ.សំណូមពរ**

- គ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- វគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនិមួយៗរបស់ខ្លួន។
- ក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិយកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេចស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធានគ.ជ.ប.ជ បានសម្រេច។

## IV. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ ពីរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការ សហប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះខាតខ្លះក្នុង កិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រយ័ត្ន ប្រយែង មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាជាមិនខាន។

## V. ទិសដៅខែមេសា ឆ្នាំ២០១៧

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួម បែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ជាអាទិ៍ៈ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ជួញដូរ និងដកហូតសរីរាង្គ ជួញដូរ និងរត់ពន្ធទារក និងកុមារ ឆ្លងដែន ការរៀបអាពាហ៍ពិពាហ៍ជំនួស ការជួញដូរពលកម្មក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។ ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។ ស.ធ

៣. រៀបចំសកម្មភាពសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ពាក់កណ្ដាល អាណត្តិទី២ ៖ ២០១៧-២០១៨) ។

៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត។

៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌ ។

៦. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត ។

៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកលអំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ ។

៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាម បណ្តាក្រសួង ស្ថាប័នអង្គការដៃគូក្នុងស្រុកនិងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត ។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

១០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១១. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ) ។

១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ ។

១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៧

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

**ចម្លងជូន៖**

-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## ការងារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អង្គភាព-ស្ថាប័នពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត បានផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ភូមិ/ឃុំ មានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត | 707 លើក | 48,096 នាក់ | 25,204 នាក់ |
| 2 | ព្រះវិហារ | ផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ និងលោកគ្រូ អ្នកគ្រូសិស្សានុសិស្ស នៅភូមិស្រអែម ស្រុកជាំក្សាន្ត ។ | លេខាធិការដ្ឋានខេត្ត | 2 លើក | 791 នាក់ | 435 នាក់ |
| 3 | កោះកុង | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅតាមភូមិឃុំ សង្កាត់ទូទាំងខេត្ត ។ | លេខាធិការដ្ឋានខេត្ត | 14 លើក | 712 នាក់ | 328 នាក់ |
| 4 | បាត់ដំបង | បានធ្វើវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ ប្រជាពលរដ្ឋ នៅឃុំបឹងរាំង ស្រុកកំរៀង។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត គណៈបញ្ជាការឯកភាព ក្រុង/ស្រុក និងអង្គការ IOM | 340 លើក | 35,283 នាក់ | 17,881 នាក់ |
| 5 | កណ្តាល | ផ្សព្វផ្សាយច្បាប់ស្តី អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ ។ | ក្រុមការងារថ្នាក់ស្រុក | 34 លើក | 2,211 នាក់ | 1,399 នាក់ |
| | | ផ្សព្វផ្សាយច្បាប់ស្តី អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសលើស្ត្រី និងកុមារ ដល់ប្រជាពលរដ្ឋ នៅឃុំគគីរ ស្រុកកៀនស្វាយ ,ឃុំជ្រៃលាស់ ឃុំពញាឮ ស្រុកពញាឮ ,ឃុំបន្ទាយដែក និងមណ្ឌលសុខភាពឃុំគគីរធំ ស្រុកកៀនស្វាយ ។ | មន្ទីរកិច្ចការនារី និងអង្គការសីលការ | 4 លើក | 264 នាក់ | 174 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ ស្តីពីទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាពទាំង១២ក្រុង ស្រុក ដល់ប្រជាពលរដ្ឋ ។ | ក្រុមការងារថ្នាក់ក្រុង/ស្រុក | 106 លើក | 29,173 នាក់ | 4,543 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | កំពត | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅស្រុកទឹក ឈូ និងស្រុកអង្គរជ័យ ។ | ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត | 2 លើក | 292 នាក់ | 140 នាក់ |
| 7 | តាកែវ | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅស្រុកទឹក ឈូ និងស្រុកអង្គរជ័យ ។ | ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត | 22 លើក | 4,793 នាក់ | 2,445 នាក់ |
| 8 | កំពង់ធំ | ផ្សព្វផ្សាយ ស្តីពីទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពល រដ្ឋនៅតាម ភូមិ ឃុំ ស្រុក ។ | ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ស្រុក | 5 | 130 នាក់ | 101 |
| 9 | សៀមរាប | ផ្សព្វផ្សាយ ស្តីពីទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់អ្នកស្ម័គ្រចិត្តយុវជនកាកបាទក្រហម និងសិស្សានុសិស្សនៅវិទ្យាល័យស្វាយធំ និងនៅសាខាកាកបាទក្រហមកម្ពុជាខេត្ត ។ | សាខាកាកបាទក្រហមកម្ពុជា | 3 លើក | 144 នាក់ | 101 នាក់ |
| | | បានផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីបែបបទ និងនិតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស នៅក្នុងស្រុកក្រឡាញ់ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត | 3 លើក | 123 នាក់ | 81 នាក់ |
| 10 | ពោធិ៍សាត់ | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សនៅតាមឃុំ សង្កាត់ ទូទាំងខេត្ត ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ,ស្រុកក្រគរ និងស្រុក ភ្នំក្រវ៉ាញ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 32 លើក | 3,402 នាក់ | 1,285 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ/ឃុំ មានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ,ស្រុកបាកាន ,ស្រុកក្រគរ ស្រុកកណ្ដៀង ,ស្រុកបាកាន ,ស្រុកភ្នំក្រវ៉ាញ និងស្រុកវាលវែង ។ | ក្រុមការងារថ្នាក់ស្រុក | 328 លើក | 80,005 នាក់ | 44,487 នាក់ |
| 11 | កំពង់ឆ្នាំង | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ ៩យ៉ាង អំពីគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក | 440 លើក | 52,526 នាក់ | 27,565 នាក់ |
| | | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | | 462 លើក | 54,348 នាក់ | 29,285 នាក់ |
| 12 | រតនៈគិរី | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 23 លើក | 609 នាក់ | 251 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 13 | ឧត្តរមានជ័យ | ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ កិច្ចការពារជនរងគ្រោះ យន្តការទេសន្តប្រវេសន៍ និងការកេងប្រវ័ញ្ចនានា ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋ ទូទាំងក្រុង/ស្រុក។ | លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក | 3 លើក | 1,774 នាក់ | 749 នាក់ |
| | | វេទិកាផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅស្រុកអន្លង់វែង ។ | | 1 លើក | 110 នាក់ | 85 នាក់ |
| 14 | ព្រះសីហនុ | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅស្រុកកំពង់សីឡា និងស្រុកព្រៃនុប។ | លេខាធិការដ្ឋានខេត្ត ក្រុង ស្រុក មន្ទីរកិច្ចការនារី និងស្នងការដ្ឋាននគរបាលខេត្ត | 4 លើក | 251 នាក់ | 162 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ/ឃុំ មានសុវត្ថិភាព ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។ | | 2 លើក | 76 នាក់ | 47 នាក់ |
| | | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។ | | 3 លើក | 424 នាក់ | 291 នាក់ |
| 15 | តាកែវ | ផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការទប់ស្កាត់ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។ | លេខាធិការដ្ឋានខេត្ត ថ្នាក់ក្រុង ស្រុក និងស្នងការដ្ឋាននគរបាលខេត្ត | 26 លើក | 11,270 នាក់ | 725 នាក់ |
| | | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការទប់ស្កាត់ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។ | | 15 លើក | 287 នាក់ | 143 នាក់ |
| 16 | ស្វាយរៀង | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅក្រុងស្វាយរៀង ក្រុងបាវិត និងស្រុកចន្ទ្រា ។ | លេខាធិការដ្ឋានថ្នាក់ក្រុង ស្រុក | 347 លើក | 15,209 នាក់ | 8,460 នាក់ |
| 17 | ព្រៃវែង | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅឃុំស្មោងត្បូង ស្រុកកំចាយមារ។ | លេខាធិការដ្ឋានថ្នាក់ ស្រុក | 1 លើក | 127 នាក់ | 65 នាក់ |

សកម្មភាពសរុបៈចំនួន: 2,929 លើក

មនុស្សសរុបចំនួន: 342,430 នាក់

ស្រីសរុបចំនួន : 166,432 នាក់

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន៣៤លើក )

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ បាន ៖ | - អញ្ជើញចុះបេសកកម្មតាមដានលើការអនុវត្តអនុសញ្ញា CEDAW នៅខេត្តពោធិសាត់ ។<br>- អញ្ជើញចូលរួមពិធីបិទវគ្គបណ្តុះបណ្តាលកម្រិតបឋមវិជ្ជាជីវៈនគរបាល និងប្រកាសតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិ ក្រោមអធិបតីភាព **សម្តេច ក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលាបណ្ឌិត្យសភានគរបាលជាតិកម្ពុជា។<br>- ដឹកនាំប្រជុំប្រកាសបញ្ចូលក្របខ័ណ្ឌមន្ត្រីនគរបាលជាតិថ្មី និងត្រួតពិនិត្យតួនាទីភារកិច្ចនៅក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។ មន្ត្រីនគរបាលជាតិក្របខ័ណ្ឌថ្មីដែលត្រូវបញ្ចូលក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានចំនួន **១៥**នាក់ (ស្រី **៥**នាក់) ។<br>- អញ្ជើញជួបប្រជុំពិភាក្សាជាមួយអង្គការ Cambodia ACTs ស្តីពីការបង្ហាញគម្រោង Child rights in the global compacts Cambodia នៅសាលប្រជុំអគ្គលេខា ធិការដ្ឋាន ។<br>- ដឹកនាំប្រជុំពិភាក្សា ស្តីពីសេចក្តីរាយការណ៍ជំហានដំបូងអំពីលទ្ធផលនៃការចុះធ្វើការសិក្សាស្រាវជ្រាវ លំហូរពលករនៅច្រកទ្វារអន្តរជាតិដូង នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។<br>- ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីកិច្ចប្រជុំជំនាញពាក់ព័ន្ធនឹងការរៀបចំបែបបទនីតិវិធីអនុវត្តលិខិតលេខ ២៥៣សជណ ស្តីពីគោលការណ៍ដោះស្រាយករណីទារកដែល កើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។<br>- អញ្ជើញចុះត្រួតពិនិត្យលើការសម្ភាសពលករដែលបញ្ជូន ត្រឡប់មកពីប្រទេសថៃ នៅច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង ។<br>- អញ្ជើញជួបពិភាក្សាការងារជាមួយអង្គការ CHILD Frontiers ដើម្បីផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងប្រព័ន្ធការពារកុមារ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។<br>- ដឹកនាំក្រុមជំនួយកិច្ចការទេសន្តប្រវេសន៍ និងក្រុមជំនួយកិច្ចការការពារជនរងគ្រោះ ចុះបេសកកម្មសហការជាមួយអង្គភាពពាក់ព័ន្ធនៅច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង ដើម្បីត្រួតពិនិត្យ និងសម្ភាសពលករដែលបញ្ជូនត្រឡប់មកពីប្រទេសថៃ ។ |

| | |
|---|---|
| | - ចូលរួមប្រជុំពាក់ព័ន្ធអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កម្ពុជា-ឥណ្ឌា នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។<br>- បានធ្វើបទបង្ហាញអំពីលទ្ធផលជំហានដំបូង ស្តីពីការចុះធ្វើការសិក្សាស្រាវជ្រាវ និងធ្វើបទសម្ភាសន៍ផ្ទាល់ជាមួយពលករកម្ពុជា ដែលបញ្ជូនត្រឡប់មកវិញតាមច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង ។<br>- បានសហការជាមួយអង្គភាពពាក់ព័ន្ធ ចុះត្រួតពិនិត្យនៅច្រកទ្វារអន្តរជាតិដូង ស្តីពីការងារពាក់ព័ន្ធនឹងលំហូរទេសន្តរប្រវេសន៍ និងជនរងគ្រោះ ។ |
| រាជធានីភ្នំពេញ | - នាយកដ្ឋានការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានចូលរួមសិក្ខាសាលាលើកទី១ ស្តីពីក្រុមអ្នកពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។<br>- នាយកដ្ឋានការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសហការជាមួយអង្គការ AAPTIP រៀបចំកិច្ចប្រជុំប្រចាំខែ ស្តីពីជំនាញស៊ើបអង្កេត និងយេនឌ័រ ក្នុងការបង្ការទប់ស្កាត់ការជួញដូរមនុស្ស ។ |
| ខេត្តបាត់ដំបង | - ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ដល់មន្ត្រីពាក់ព័ន្ធក្រុង/ស្រុក ឃុំ/សង្កាត់ ស្តីពីយុត្តិធម៌ អនីតិជន និងស្ត្រី រៀបចំដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារស្នើបាត់ដំបង ។<br>- បានចូលរួមជាវាគ្មិន ក្នុងវេទិកាផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងឱកាសការងារនៅក្នុងប្រទេស នៅឃុំបឹងរាំង ស្រុកកំរៀង។<br>- ស្នងការដ្ឋាននគរបាលខេត្ត ចាត់តាំងមន្ត្រីជំនាញចំនួន០១នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសអំពើជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា រៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអង្គការ AAPTIP មានសិក្ខាកាមសរុបចំនួន២៤នាក់(ស្រី)។ |
| ខេត្តឧត្តរមានជ័យ | - ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលាខេត្ត សរុបអ្នកចូលរួមចំនួន៤៤នាក់ (ស្រី៣៨នាក់)។ |
| ខេត្តសៀមរាប | - ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សម្របសម្រួលរៀបចំកិច្ចប្រជុំប្រចាំខែមេសា ឆ្នាំ២០១៧ របស់ក្រុមការងារទេសន្តរប្រវេសន៍ ដែលមានអ្នកចូលរួមសរុបចំនួន៤០នាក់ (ស្រី២១នាក់)។<br>- មន្ទីរព័ត៌មានខេត្ត សហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរ ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គភាពពាក់ព័ន្ធ ចូលរួមជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ទនាមតិ និងផ្សព្វផ្សាយច្បាប់ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកមិនស្របច្បាប់ ជាពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលនៅក្នុងខេត្ត ០៩ប្រធានបទ ។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានជួបប្រជុំពិភាក្សាជាមួយអង្គការម្លូហាស៊ី ស្តីពីការរំលោភបំពានលើកុមារ និង ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលជនបរទេសបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា និងការសហការរវាងអង្គការជាមួយការិយាល័យជំនាញ មានចំនួន០៨នាក់ និងបុគ្គលិកអង្គការចំនួន០៤នាក់ ។ |

| | |
|---|---|
| ខេត្តស្ទឹងត្រែង | - គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយ ក្រុមលេខាធិការដ្ឋានថ្នាក់ក្រុង បានធ្វើការប្រជុំប្រចាំខែមេសា ដើម្បីផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់សមាជិកដែលមានចំនួន១៥នាក់(ស្រី៧នាក់)។ |
| ខេត្តកំពង់ចាម | - នាយរងការិយាល័យទទួលបន្ទុកប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ និងទូរទស្សន៍ជាតិខេត្ត ក្រោមប្រធានបទផ្សព្វផ្សាយ និងការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ ដែលជ្រកក្រោមស្លាកខារ៉ាអូខេ និងហាងម៉ាស្សា នៅមន្ទីរព័ត៌មានខខេត្ត ។ |
| ខេត្តបន្ទាយមានជ័យ | - ស្នងការដ្ឋាននគរបាលខេត្ត បានចាត់បញ្ជូនមន្ត្រីការិយាល័យជំនាញចំនួន០៣រូប ប្រចាំការនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីសម្ភាសពលករដែលអាជ្ញាធរថៃបញ្ជូនមក និងស្រាវជ្រាវរកមុខសញ្ញាពាក់ព័ន្ធអំពើជួញដូរមនុស្ស ។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមវេទិកា សំណួរ ចម្លើយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការយល់ដឹងអំពីអំពើជួញដូរមនុស្ស បានចំនួន០៤ឃុំ (ឃុំតាប៉ែន ឃុំទ្រាស ,ឃុំតាផូ ,ឃុំផ្គាំ )។<br>- បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី១ និងផ្សព្វផ្សាយទិសដៅបន្តការងារក្នុងឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ។ |
| ខេត្តកំពត | - គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយ ក្រុមលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ ដើម្បីត្រួតពិនិត្យការគ្រប់គ្រងអនុវត្តការងារដឹកនាំ និងជំរុញឲ្យក្រុមការងារខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដើម្បីគ្រប់គ្រងសភាពការណ៍បទល្មើស និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋនៅក្នុងខេត្តទាំងមូល ។ |
| ព្រៃវែង | - គណៈកម្មាធិការពិគ្រោះយោបល់ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការប្រជុំប្រចាំខែ ដើម្បីផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ឲ្យពួកគាត់ជួយផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនតាមរយៈ ពិធីមង្គលការ ពិធីបុណ្យ និងពិធីកម្សាន្តផ្សេងៗ ។ |
| ស្វាយរៀង | - ស្នងការដ្ឋាននគរបាលខេត្ត បានចាត់បញ្ជូនមន្ត្រីការិយាល័យជំនាញចំនួន០១រូប ទៅចូលរួមវគ្គហ្វឹកហ្វឺនបន្ថែមលើកទី២ ស្តីពីជំនាញស៊ើបអង្កេត អំពីអំពើជួញដូរមនុស្ស ដល់មន្ត្រីនគរបាលជាស្ត្រី នៅសណ្ឋាគារ Green Palace រាជធានីភ្នំពេញ ។ |
| ខេត្តកណ្តាល | - ក្រុមការងារលេខាធិការដ្ឋានថ្នាក់ស្រុក បានបើកកិច្ចប្រជុំប្រចាំខែ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួម១២៦នាក់ ស្រី៩០នាក់(០៥លើក)។ |